ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោត
## រយៈពេល ៣ឆ្នាំ ( កញ្ញា ២០២៥ - សីហា ២០២៨ )

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ព្រែកត្នោត |
| ភូមិ | ៖ ព្រែកត្នោត |
| សង្កាត់ | ៖ ព្រែកត្នោត |
| ក្រុង | ៖ បូកគោ |
| ខេត្ត | ៖ កំពត |

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**......................................................................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.............................................២

ក- ប្រជាពលរដ្ឋ..................................................................................២

ខ- មុខរបរ.........................................................................................៣

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**...............៣

ក- ទីតាំង..........................................................................................៣

ខ- ដែននេសាទ...................................................................................៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស........................................៣

ឃ- ធនធានជលផល.............................................................................៤

**៤- ការធ្វើនេសាទ**.............................................................................៤

ក- អ្នកនេសាទ...................................................................................៤

ខ- ឧបករណ៍នេសាទ............................................................................៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..........................................................៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**....................................................៧

**ក- ទស្សនៈវិស័យ**..............................................................................៧

**ខ- គោលបំណង**................................................................................៧

**គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**...........................................៧

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**...............................................៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.......................................៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ...............៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល................................................៨

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ....................................................៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល....................................................១០

គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.............................................១១

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.......................១២

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.....................១២

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង...........................................................១៣

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**..................................១៤

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ...........................១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ..............................១៥

គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ...........................១៦

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ................................១៧

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**..................១៨

គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ..........១៨

គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ..........................១៨

**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**.......................................................................១៩
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន.......................................................................១៩
គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..........................................................២០
**ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**.........................................................................២០
**ង. ផែនការយុទ្ធសាស្រ្ត**.......................................................................................................២១
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី រយៈពេល៣ឆ្នាំ**...........................២២
**តារាងពេលវេលាការងារ**.........................................................................................២៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទព្រែកត្នោត ស្ថិតនៅភូមិព្រែកត្នោត សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ បន្ទាប់មកបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ១២៣ ប្រក.កសក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។ សហគមន៍នេសាទនេះ បានរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការជាថ្មីស្របតាមលក្ខន្តិកៈសហគមន៍នេសាទ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយមានគណៈកម្មការចំនួន៩នាក់ ស្រី១នាក់ និងមានក្រុមល្បាត១៣នាក់។ សហគមន៍នេសាទព្រែកត្នោត មានសមាជិកសរុបចំនួន២៤៨នាក់ ស្រី៨០នាក់ ត្រូវនឹង២៤៨គ្រួសារ ។

កន្លងមកសហគមន៍នេសាទព្រែកត្នោត បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ ដោយបានកំណត់ព្រំប្រទល់ផែនទីកន្លែងសហគមន៍នេសាទព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងដែលបានបែងចែកតួនាទី និងភារកិច្ចការទទួលខុសត្រូវរបស់គណៈកម្មការ និងសមាជិកសហគន៍ដែលមានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិនិងអាជ្ញាធរមូលដ្ឋាន។ ចំពោះផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទគណៈកម្មការនិងសមាជិកសហគមន៍សហការជាមួយដៃគូពាក់ព័ន្ធបានអនុវត្តសកម្មភាពសំខាន់ៗរួមមានការចូលរួមប្រជុំនិងបិទផ្សាយផែនទីកន្លែងសហគមន៍នេសាទ រៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ បង្កើតធនាគារក្តាមសេះ ដើម្បីបង្កើនផលស្តុកក្តាមសេះក្នុងធម្មជាតិ ផ្តួចផ្តើមសកម្មភាពមុខរបរតាមរយៈសេវាកម្មទេសចរណ៍ជលផលរបស់សហគមន៍នេសាទ បានចូលរួមយុទ្ធនាការផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា បានរៀបចំក្រុមល្បាតរបស់សហគមន៍នេសាទ និងបានចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទដែលកើតមានក្នុងកន្លែងសហគមន៍នេសាទ។ សកម្មភាពទាំងនេះសបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាពស្របតាមផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទរបស់ខ្លួន ទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទព្រែកត្នោត កំពុងខិតខំគៀងគរការចូលរួមធនធាននិងការគាំទ្រនានាក្នុងការដោះស្រាយបញ្ហាប្រឈមដែលនៅតែកើតមានឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីសកម្មភាពនេសាទលើសកម្រិត ការនេសាទដោយប្រើប្រាស់ស្បៃមុង តម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ មានដូចជា ទូកអូសស្រទាប់បាតនៅទឹករាក់ ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម ព្រមទាំងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូច នេសាទជាប្រពៃណី និងនេសាទខ្នាតធំ។ សហគមន៍នេសាទសង្កេតឃើញថា ជះឥទ្ធិពលដល់ផលចាប់ត្រី និងវារីសត្វ សមុទ្រផ្សេងៗមានការថយចុះ
- ការថយចុះប្រព័ន្ធអេកូស៊ីស្ទែមជលផលសមុទ្រ ដូចជា ជម្រកជលផលសមុទ្រ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្មដែលកំពុងរងផលប៉ះពាល់ពីការនេសាទដែលបំផ្លិចបំផ្លាញ ការអភិវឌ្ឍមិនសមស្រប ជាដើម
- សមត្ថភាព និងចំណេះដឹងរបស់គណៈកម្មការ និងសមាជិកសហគមន៍នេសាទនៅមានកម្រិត ដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន ឬសហគ្រប់គ្រងនៅមានកម្រិត
- ការជ្រើសរើសមុខរបរមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយលើផលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃផលផលិតផលកសិកម្មដែលកំណត់ដោយឈ្មួញកណ្តាលក្នុងតំបន់ ពិបាកក្នុងការទទួលបានតម្លៃបន្ថែមលើផលផលិតផលដោយសារគុណភាពផលផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្តើម និងជំនាញលើ

លើមុខរបរ ដូចជាការបង្កើនសេវាកម្មទេសចរណ៍ជលផល វារីវប្បកម្មដែលមិនប្រើចំណីជាដើម

- ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិដែលប៉ះពាល់លើការប្រកបរបរនេសាទ សេវាទេសចរណ៍ជលផល លំនៅដ្ឋាន និងគុណភាពទឹកសមុទ្រ ដូចជា កំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រ អាចនឹងប៉ះពាល់ដល់ទេសចរណ៍ជលផល និងវារីវប្បកម្មសមុទ្រ
- ការចោលសំរាម ផ្លាស្ទិក និងកាកសំណល់នានាដែលនាំឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពនៅក្នុងសហគមន៍នេសាទ
- សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជា ការងាររដ្ឋបាល ការអនុវត្តសកម្មភាព ការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- លទ្ធភាពចូលរួមអនុវត្តច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជាឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាត ដែលធន នឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ស្តីពីជលផលមិនបានដិតដល់ជាប្រចាំ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រែកត្នោត ចាប់ពីខែមិថុនា ឆ្នាំ២០២០ ដល់ ខែមិថុនា ឆ្នាំ២០២៣ លេខ២១៤៣ជផ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ត្រូវរៀបចំកែសម្រួលឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទសកម្មភាពនានាស្របនឹងនិន្នាការថ្មីៗ តម្រូវការសហគមន៍នេសាទ និងការប៉ាន់ប្រមាណថវិកាដោយផ្តោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការគ្រប់គ្រងសកម្មភាពនេសាទ និងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន១៦៨៣នាក់ ស្រី៨១៨នាក់ ក្នុងនោះមានចំនួន៣២៧ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ៧៨នាក់ ស្រី៣៥នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៩២នាក់ ស្រី៥៤នាក់ កម្រិតវិទ្យាល័យចំនួន៤នាក់ ស្រីចំនួន១នាក់ និងកម្រិតឧត្តមសិក្សាគ្មាន ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១០នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១២នាក់ ស្រី៥នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន២១នាក់ ស្រី២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន១៥នាក់ ស្រី៧នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន៦នាក់ ស្រី២នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ ចំនួន ១១៥ គ្រួសារ
- ធ្វើស្រែ ចំនួន ២៥ គ្រួសារ ទំហំ៣៥ ហិកតា

- ធ្វើចំការ ចំនួន ២ គ្រួសារ ទំហំ០,៣-០,៨ហិកតា
- ដាំបន្លែ ចំនួន ៩ គ្រួសារ
- ធ្វើវារីវប្បកម្ម ចំនួន ១៣ គ្រួសារ
- ជាងផ្ទះ ចំនួន ៣ គ្រួសារ
- លក់ដូរ ចំនួន ៥៥ គ្រួសារ
- កម្មករ ចំនួន ១៤ គ្រួសារ
- កែច្នៃផលនេសាទចំនួន ២ គ្រួសារ (បង្គាក្រៀម)
- ចិញ្ចឹមសត្វ ចំនួន ១០ គ្រួសារ ។

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៩ ០៤៣ ៥០០ រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ព្រែកត្នោត ដែលជាដែននេសាទសមុទ្រ រួមមាន កន្លែងនេសាទតាមឆ្នេរ ស្មៅសមុទ្រ កន្លែងអភិរក្សជលផល នាទីព្រៃកោងកាង វាលភក់ គឺជាដែននេសាទសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។ សហគមន៍នេសាទព្រែកត្នោត ត្រូវបានកំណត់និយាមកា ដូចមានចែងក្នុងកិច្ចព្រមព្រៀង ដែលបានទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

សហគមន៍នេសាទព្រែកត្នោត មានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត
- ខាងត្បូងជាប់នឹងលំហសមុទ្រ
- ខាងកើតជាប់នឹងកន្លែងសហគមន៍នេសាទព្រែកត្នោត
- ខាងលិចជាប់នឹងកន្លែងសហគមន៍នេសាទត្រពាំងរពៅ ។

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ព្រែកត្នោត មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទ ទំហំ ១១៦៨ហិកតា មានដែននេសាទតំបន់ឆ្នេរ រួមមាន លំហសមុទ្រចំនួន១ វាលភក់ចំនួន១ និងនាទីព្រៃកោងកាងចំនួន១៖

- លំហសមុទ្រ ទំហំ ១០៧៤,៣ ហិកតា នេសាទពេញមួយឆ្នាំ
- វាលភក់ ទំហំ ៦៩,៨ ហិកតា នេសាទពេញមួយឆ្នាំ
- នាទីព្រៃកោងកាង ទំហំ ២៣,៩ ហិកតា នេសាទពេញមួយឆ្នាំ ។

### គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល

សហគមន៍នេសាទព្រែកត្នោត បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សជលផលមួយកន្លែង ទំហំ៤៨ហិកតា។ កន្លែងអភិរក្សជលផលនេះ ត្រូវបានធ្វើការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំ (ហិកតា) | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្សជលផលចំណុចថ្មបីដុំ | ៤៨ | អភិរក្សជលផល |
| ២ | កន្លែងអភិរក្សជលផលខោសខ្ពស់ | ៦៦ | អភិរក្សជលផល |

**ឃ. ធនធានជលផល**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍នេសាទព្រែកត្នោត បានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធាជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ។ ក្រុមការងារនិងសមាជិកសហគមន៍នេសាទបានអង្កេតឃើញថា ធនធានជលផលក្នុងសហគមន៍នេសាទនេះមានដូចជា៖

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្តចិន ត្រីក្បក ត្រីក្អុក ត្រីស្លុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកាឡាងំ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រែ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកន្ទប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹក គ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ធាយ បាលង្គ័កាស កញ្ជ្រា អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៊ឹង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ជូរ ដើមឡេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១១៥នាក់ ស្រី៨០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍៣៥នាក់ស្រី១០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៨០នាក់ ក្នុងមួយឆ្នាំ។

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួន ឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវនេសាទ |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ១៥ | ១៦ដៃ(១ដៃ=៦០ម) | ១០០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ១៥ | ២០០ដៃ(១ដៃ=៣០ម) | ៦០០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងក្តាម | ម៉ែត្រ | ៦ | ១៥០ដៃ(១ដៃ=៥០ម) | ៧៥០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| លបក្តាម | លប | ៧ | ១៥០គ្រឿង/គ្រួសារ | ០,៣ មx ០,៥ ម | ពេញមួយឆ្នាំ |
| លបត្រី | លប | ៥ | ១៥លប/គ្រួសារ | ០,៨ មx១,២ ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ២ | ៣០០-១០០០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| សន្ទូចត្រីស្លង់/តុកកែ អាំងកឹយ/អណ្តែងពុយ ត្រីក្អុក | ផ្លែ | ៧ | ៨ផ្លែ/គ្រួសារ | ផ្លែលេខ៤-៧ | ពេញមួយឆ្នាំ |
| សន្ទូចរនងមឹក | ផ្លែ | ១ | ៣០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| ឈិបរុញដៃ | គ្រឿង | ៧ | ១គ្រឿង/គ្រួសារ | ៦ ម x ៦ម | ពេញមួយឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| រាវបង្គា | នាក់ | ៦ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| រាវក្រែងឈាម | នាក់ | ១៣ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាក់ខ្យងចាក់ច្រែង | នាក់ | ៨ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាក់បង្គា | នាក់ | ៧ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| លូកក្តាមថ្ម | នាក់ | ៨ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាប់ក្តាមជ័រ | នាក់ | ៨ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦០គ្រឿង | ៧០០-៣០០០គីឡូក្រាម | ៦-៣៦ សេះ |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| **ឧបករណ៍នេសាទ** | **ឯកតា** | **ចំនួនគ្រួសារ** | **ចំនួនឧបករណ៍នេសាទ** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....)** |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៧ | ១៦ដៃ(១ដៃ=៦០ម) | ១០០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងត្រីផ្ទោង | ម៉ែត្រ | ៥ | ៥ដៃ(១ដៃ=៦០ម) | ៨០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ២ | ៥ដៃ(១ដៃ=៦០ម) | ៨០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងក្តាម | ម៉ែត្រ | ៣ | ១៥០ដៃ(១ដៃ=៥០ម) | ៧៥០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងត្រីកាម៉ុង | ម៉ែត្រ | ៣ | ១០ដៃ(១ដៃ=៦០ម) | ១២០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| មងត្រីកន្តាំង | ម៉ែត្រ | ៥ | ១៦ដៃ(១ដៃ=៦០ម) | ១០០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| លបក្តាម | លប | ៣ | ៥០០លប/គ្រួសារ | ០,៣.មx០,៥ម | ពេញមួយឆ្នាំ |
| រនងផ្ទាក់មឹក | គ្រាប់ | ១ | ៨០០០គ្រាប់/គ្រួសារ | ៨០០០គ្រាប់/គ្រួសារ | ពេញមួយឆ្នាំ |
| សន្ទូចរនងមឹក | ផ្លែ | ១ | ៣០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| ឈិបរុញដៃ | គ្រឿង | ៥ | ១គ្រឿង/គ្រួសារ | ១គ្រឿង/គ្រួសារ | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៧០០-៣០០០គីឡូក្រាម | ៦-៣៦សេះ |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| **ប្រភេទ ឧបករណ៍** | **ឯកតា** | **ចំនួន នាក់** | **ចំនួន ឧបករណ៍នេសាទ** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....)** |
|---|---|---|---|---|---|
| មងក្តាម | ម៉ែត្រ | ១០ | ១៥០ដៃ(១ដៃ=៥០ម) | ៧៥០០ម៉ែត្រ/គ្រួសារ | ពេញមួយឆ្នាំ |
| លបក្តាម | លប | ២២ | ១០០០លប/គ្រួសារ | ០,៣.មx០,៥ម | ពេញមួយឆ្នាំ |
| លបត្រី | លប | ១៣ | ១០លប/គ្រួសារ | ០,៨មx១,២ម | ពេញមួយឆ្នាំ |
| លូកក្តាមថ្ម ក្តាមជំរ | នាក់ | ១៥ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ឈិបរុញដៃ | គ្រឿង | ២០ | ១-២គ្រឿង/គ្រួសារ | ៦មx៦ម | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| **មធ្យោបាយធ្វើដំណើរ** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៧០០-៣០០០ គីឡូក្រាម | ៦-៣៦ សេះ |
| ប្រើម៉ូតូ | ១០ គ្រឿង | | - |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| **ប្រភេទផលនេសាទ** | **បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទជាសមាជិក)** | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីគ្រប់ប្រភេទ | ១ ៨០០ គីឡូក្រាម | ១ ៨០០ គីឡូក្រាម | ៣ ៦០០ គីឡូក្រាម |
| បង្គា | ២៧០ គីឡូក្រាម | ៤៥០ គីឡូក្រាម | ៧២០ គីឡូក្រាម |
| ក្តាម | ១ ៨០០ គីឡូក្រាម | ១ ៨០០ គីឡូក្រាម | ៣ ៦០០ គីឡូក្រាម |
| មឹក ខ្យង និងគ្រែងឈាម | ៣ ៦០០ គីឡូក្រាម | ៣ ១៥០ គីឡូក្រាម | ៦ ៧៥០ គីឡូក្រាម |
| **សរុប** | **៧៩២០ គីឡូក្រាម** | **៧ ២០០ គីឡូក្រាម** | **១៤ ៦៧០ គីឡូក្រាម** |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទព្រែកត្នោត មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងនេសាទសហគមន៍ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាសហគមន៍នេសាទ បានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានជលផល។

### គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ

### ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង

### គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចកំពង់តាអួន ខាងក្រៅព្រៃកោងកាង ទំហំ១៥ម៉ែត្រ x ១៥ម៉ែត្រ ស្ថិតក្នុងភូមិព្រែកត្នោត សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ៥០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២៦ | សីហា ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨ម x ១២ម ធ្វើពីបេតុងគ្រឿងក្រោម រួមផ្សំគ្រឿងឈើ ហ្វីប្រូដ័រ បន្ទប់មួយជ្រុងរៀបជញ្ជាំងក្តារ តយ៉ាបបីជ្រុង និងមានបង្គន់អនាម័យ | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍ | ១៥ ០០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២៦ | សីហា ២០២៨ |
| រៀបចំតបណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ | ១ ០០០ | | ២០២៦ | សីហា ២០២៨ |
| តនិងរៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជ័រ ២ ចំណុះ ៣ ៥០០លីត្រ | មានទឹកស្អាតប្រើប្រាស់ | ១ ៥០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារសម្រាប់ស.ន ធ្វើការ | ២ ០០០ | | | |

(ស.ន = សហគមន៍នេសាទ)

### គ២-ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី១នៃខែ រៀងរាល់ខែឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត<br>-លើកបញ្ហាប្រឈម និងតម្រូវការ | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយអាជ្ញាធរសង្កាត់ ក្រុង ឬអង្គភាពពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលការងារ<br>-បញ្ចូលផែនការគ្រប់គ្រងក្នុងផែនការអភិវឌ្ឍន៍សង្កាត់<br>-មានដំណោះស្រាយ | ៥៤០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចូលរួមប្រជុំជាមួយបណ្តាញសហគមន៍នេសាទថ្នាក់ស្រុក ឬថ្នាក់ខេត្ត | | | -អាជ្ញាធរស្រុក/ខេត្ត<br>-បណ្តាញស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពជម្រុញការចុះបញ្ជីទូកម៉ាស៊ីនសហការជាមួយអាជ្ញាធរ និងជំនាញពាក់ព័ន្ធជាប្រចាំ | - ចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- នាវានេសាទដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសនេសាទថយចុះ | ៦០០ | គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| សម្ភារការិយាល័យ៖<br>LCD with Screen, ទិញក្រដាស់ បិច, ព្រីន កូពី, ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ២ ០០០ | គណៈកម្មការ | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

### គ៣-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រ មាណ តម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីសហគមន៍កសិកម្ម ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងស.ន<br>-ការរៀបចំនិងទុកដាក់សម្រាម | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហកមន៍មាន | ២ ៥៨០ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | មករា-មិថុនា/ រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| -បទពិសោធន៍នានាទទួលបាន | ការកើនឡើងប្រជាពលរដ្ឋអាច រកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | | | | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| -ចែកចាយឯកសារផែនការប្រើ ឧបករណ៍នេសាទដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | | |
| ផ្សព្វផ្សាយដល់សមាជិកស.ន ដើម្បីចុះបញ្ជី ទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទ បានចុះបញ្ជីទូកម៉ាស៊ីន តាមច្បាប់ | ៤៥០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| ២.ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ និងសមាជិក ស.ន បានយល់ដឹង និងអាច អនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១ ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ(២នាក់) | ៣៦០ | គណៈកម្មការស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទ បានយល់ដឹង និងអាចអនុវត្តន៍ បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំជំនាញសម្របសម្រួល និងការដោះស្រាយទំនាស់ | គណៈកម្មការ និងសមាជិក ស.ន បានយល់ដឹង និងអាច អនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៤០០ | | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

## គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍ព្រែកត្នោត (គណៈកម្មការ និងសមាជិកសហគមន៍ | ពេញរដូវនេសាទ ៣ ឆ្នាំ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងត្រីឆ្តង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អុក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| នេសាទ) | | មងត្រីព្រលួស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រខុប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ធាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្ដាម | ក្រឡា ៨ ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្លប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងត្រីកន្ទុយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីការ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគួន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្ដាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រើសច្រើន/កន្ទុយកណ្ដុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមកៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខ្ញូវ ឬមងខ្ញូវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនកេរ ឬមងកេរ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងធ្នាក់មឹក | - | ៨០០គ្រាប់/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | ឈិបរុញដៃ | មិនកំណត់ | មិនកំណត់ | |
| | | រាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | រាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្ដាមថ្ម ជ័រ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | មិនកំណត់ | មិនកំណត់ | |

(ម = ម៉ែត្រ, ស.ម = សង្ទីម៉ែត្រ)

## គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ៖<br>-តាមមេក្រូ ២៤ដង/ឆ្នាំ<br>-បិទ ចែកឯកសារ ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ ២ដង/ឆ្នាំ មិថុនា/ធ្នូរៀងរាល់ឆ្នាំ | - យល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធាន<br>- ការយល់ដឹងពីផែនការគ្រប់គ្រង<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១ ៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការល្បាតប្រចាំខែ | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | កញ្ញា ២០២៥ | សីហា ២០២៨ |
| អនុវត្តន៍ផែនការល្បាត៖ រៀបចំកំលាំងចុះល្បាតជាក់ស្តែងសហការជាមួយ អាជ្ញាធរ អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ (៦ដង/ខែ = ២១៦/ដង) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១៥ ៥៥២ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| មធ្យោបាយនិងសម្ភារ<br>-សាំង និងប្រេងបាត<br>-អាវ ស្បែកជើង មួក ពិល អាវភ្លៀង អាវពោង អាយកូម ម៉ាស៊ីនថត កែវយឹត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣ ៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ទិញទូកនិងម៉ាស៊ីន២គ្រឿង | មានមធ្យោបាយចុះល្បាត | ៤ ០០០ | | | |

## គ.៦ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អកន្លែងនេសាទសហគមន៍ ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហិកតា) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ព្រែកត្នោត | ១១៦៨ | ១១៦៨ | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ អ្នកពាក់ព័ន្ធ | ១០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ២ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ១ ២០០ | | |
| | | | ស្លាកសញ្ញា ១០ផ្ទាំង១,២មx១ម ធ្វើពីគ្រឿងដែក | ២ ០០០ | | |
| | | | រកទីតាំងតាមនិយាមកានិងបោះបង្គោលព្រំប្រទល់ ស.នលើគោក ៧បង្គោល ធ្វើពីបេតុង សរសៃដែក | ១ ០៥០ | | |
| | | | បោះបង្គោលព្រំប្រទល់សហគមន៍នេសាទក្នុងទឹក ៥បង្គោល ធ្វើពីបេតុងទំហំ០,៣មx៨ម | ៦ ០០០ | | |

(ស.ន = សហគមន៍នេសាទ, ម = ម៉ែត្រ)

## គ.៧ ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះផែន នេសាទ | ទំហំ ត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃ ការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អភិរក្សជលផល<br>ចំណុចថ្មបាដុំ<br>៤៨ ហិកតា<br>386059-1169287<br>385387-1169298<br>385370-1169998<br>386068-1169996<br> | ៤៨ | -ស្មៅសមុទ្រ<br>-ត្រីកាតាំង<br>-ក្តាមសេះ<br>-ត្រីផ្សោត<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ៤៥០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ចុះរកទីតាំងដាក់ស្តែងតាម និយាមកា | ៣០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ គ្រឿងដែក (សាជី) ចំនួន៤បង្គោល | ២ ៨០០ | | |
| | | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុងចំនួន១០០ ប្រអប់ | ១០ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ | ២ ០០០ | | |
| អភិរក្សជលផល<br>ចំណុចខោសខ្ពស់<br>៦៦ ហិកតា<br>386552-1170077<br>387752-1169433<br>387538-1169003<br>386350-1169615 | ៦៦ | | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលរបស់ស.ន និងហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ៥០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ចុះសិក្សាប្រមូលព័ត៌មាន | ៥០០ | | |
| | | | ចុះរកទីតាំងដាក់ស្តែងតាម និយាមកា | ៣០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ គ្រឿងដែក (សាជី) ចំនួន៤បង្គោល | ២ ៨០០ | | |
| | | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុងចំនួន១០០ ប្រអប់ | ១០ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៦០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ | ២ ០០០ | | |
| | ១០០ម x ១០០ម | | បង្កើតកន្លែងស្មៅសមុទ្រ ដើម្បីបង្កើនផលស្តុកធម្មជាតិ ដោយពង្រាយឧបករណ៍ស៊ីឡាំងស្មៅសមុទ្រសិប្បនិម្មិត ដែលជារបបគំហើញថ្មីមកពីប្រទេសជប៉ុន | ១៤ ០០០ | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ, ម = ម៉ែត្រ)

## គ.៨ **ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះពងរបស់សហគមន៍នេសាទ**

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះពង ត្រូវរៀបចំឡើងដើម្បីបង្កើនផលស្តុកធម្មជាតិ នៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះផែននេសាទ | ទំហំ (ហិកតា) | ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ស្ថិតក្នុងកន្លែងនេសាទសហគមន៍ព្រែកត្នោត<br>385973-1170222<br>385986-1170123<br>385885-1170119<br>385873-1170219<br><br>សាកល្បង<br>385973 -1170222<br>385976-1170197<br>385951-1170196<br>385948 -1170221 | ១<br><br>សាកល្បង<br>ជំហានទី១ទំហំ<br>២៥មx២៥ម | -ក្តាមសេះ<br>-ស្មៅសមុទ្រ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្តាមសេះពង | ៣៦០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | ជួសជុលស្ថានីយ៍១កន្លែងនិងស្ពានដើរជុំវិញស្ថានីយ៍ធ្វើពីឈើ និងសម្ភារជាង | ៥ ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្តាមសេះ និងព័ទ្ធស្បៃមុង | ៥០០ | | |
| | | | ពង្រាយប្រអប់ថ្មបេតុងត្រីសិប្បនិម្មិតធ្វើពី ចំនួន១០ប្រអប់ថ្មបេតុង | ៤ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្តាម និងមេក្តាមពង | ៥០០ | | |
| | | | ទិញឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់កូនក្តាមសេះ | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |

(ម = ម៉ែត្រ)

## គ.៩ **ផែនការគ្រប់គ្រងព្រៃកោងកាង**

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះផែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ២៣,៩ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ២០ស.ម x ២០ស.ម x ១,៥ម ចំនួន១០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោងកាង សហគមន៍នេសាទព្រែកត្នោត | | ៥០០ | | |
| | | | ដាក់ស្លាកសញ្ញាព្រៃកោងកាង ២ ស្លាក ២,៥មx១,៥ម ធ្វើពីគ្រឿងដែកចាក់បេតុង | | ៨០០ | | |
| | | | ថែរក្សា ការពារ | | - | | |
| វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ ៦៩,៨ ហិកតា | ១០ | ព្រៃកោងកាង | ផ្សព្វផ្សាយពីព្រៃកោងកាងឱ្យទូលំទូលាយ | ប្រជុំ | ៣០០ | កញ្ញា<br>២០២៥ | សីហា<br>២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងជាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង | | ៨០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | | | |
| | | | រៀបចំថ្នាលបណ្ដុះកូនកោងកាង បង្គោលឈើ និងស្បៃ ១០ម x ២០ម | ១ ០០០ | មិថុនា ២០២៥ | ឧសភា ២០២៨ |
| | | | បណ្ដុះកូនកោងកាងចំនួន៧០ ០០០ដើម (១ហិកតាx៧០០០ដើម) | ៧០ ០០០ | | |
| | | | ដាំកូនកោងកាងចំនួន ១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | ៣ ០០០ | | |
| | | | ថែទាំដើមកោងកាង ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ រយៈពេល៣ខែ | ១ ០០០ | | |
| | | | ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/អាទិត្យ ពី៣ខែដល់៦ខែ | ១ ០០០ | | |
| | | | ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ ពី៦ខែឡើងទៅ | ១ ២០០ | | |

(ម = ម៉ែត្រ, ស.ម = សង្ទីម៉ែត្រ)

## ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

### គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការបណ្ដុះបណ្ដាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | -មានចំណេះដឹងចិញ្ចឹមគ្រែងឈាម<br>-យកទៅអនុវត្តជាក់ស្ដែងបាន | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចិញ្ចឹមក្ដាមថ្ម | -មានចំណេះដឹងចិញ្ចឹមក្ដាមថ្ម<br>-យកទៅអនុវត្តជាក់ស្ដែងបាន | ៩០០ | គណៈកម្មការនិងសមាជិកស.ន | | |
| ចិញ្ចឹមត្រីឆ្លង់ និងត្រីទឹកកៃ | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | | |
| កែច្នៃផលនេសាទ | | ៩០០ | | | |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | | |
| បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ | -មានចំណេះដឹង<br>-មានមុខរបរខ្នាតតូច ឬសិប្បកម្ម<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | | |
| ជំនាញវិជ្ជាជីវៈលើការផ្ដល់សេវាទេសចរណ៍ជលផល | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលកសិកម្ម | ១ ០០០ | គណៈកម្មការនិងសមាជិស.ន | | |
| ២.ទស្សនៈកិច្ចសិក្សា | | ២ ៥០០ | គណៈកម្មការនិងសមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| | -ក្រុមរោងលម្ហែ (កញ្ចុះ) | | | | |
| បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈកម្មការ និងសមាជិកស.ន | គណៈកម្មការ និងស្ត្រីមានមានការយល់ដឹងពីសហគ្រិនភាពប្រមាណ ២០ភាគរយ និងអាចអនុវត្តន៍ក្នុងសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម | ៥០០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| ៣.ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម | -មានក្រុមចិញ្ចឹមគ្រែងឈាម ក្តាមថ្ម<br>-មានគ្រែងឈាម ក្តាមផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ក្រុមចិញ្ចឹមក្តាមថ្ម | | | | | |
| ក្រុមចិញ្ចឹមត្រីឆ្តង់ និងត្រីតុកែ | -មានក្រុមចិ.ត្រីឆ្តង់ កង្កែប អន្ទង់ សត្វ<br>-មានបន្លែផ្គត់ផ្គង់ដល់កន្លែងទេសចរណ៍ជលផលនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | | |
